# II. ទីស្តីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៧៧ អនក្រ**

**ស្តីពីការកិច្ច និង រចនាសម្ព័ន្ធទូទៅនៃ**

**កងរាជអាវុធហត្ថ**

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០២ កក្កដា ១៩៩៣ ស្តីពីការតែងតាំងសហអគ្គមេបញ្ជាការនៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីការកិច្ចនិងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ

-បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិនិងក្រុមប្រឹក្សាអ្នកច្បាប់អមនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១ :** កងរាជអាវុធហត្ថដែលគ្រប់គ្រងដោយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់ របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅ ។ សហរដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និង ជាអ្នកផ្តល់សំភារៈ និង ថវិកាសំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ ។ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទមានភារៈគ្រប់គ្រងសំដៅហ្វឹកហ្វឺន

កសាងរៀបចំកងរាជអាវុធហត្ថអោយរីកចំរើន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រង តួនាទី និង ភារកិច្ចរបស់ខ្លួន ។

**មាត្រា ៣ :** កងរាជអាវុធហត្ថជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានស្វ័យភាពក្នុងកិច្ច អនុវត្តច្បាប់កងរាជអាវុធហត្ថមានសកម្មភាពផ្នែកប៉ូលីសដែលមានឧបនិស្ស័យជាអន្តរក្រសួង ។ សមត្ថកិច្ចកងរាជអាវុធហត្ថត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ទៅលើពលរដ្ឋស៊ីវិលព្រមទាំងទៅលើយោធាក្នុងជួរកងទ័ពផង ។

**មាត្រា ៤ :** កងរាជអាវុធហត្ថមានភារកិច្ច :

### ក.រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល :

-រក្សាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ

-រ៉ាប់រងអោយមានការគោរពច្បាប់ និង បទបញ្ជាទាំងឡាយ

-ផ្តល់ពត៌មាន និង ជួយសង្គ្រោះពលរដ្ឋស៊ីវិល

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

### ខ.រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ :

-ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និង ទោសកម្ម

-ធ្វើកំណត់ហេតុអំពីបទល្មើស

-ប្រមូលផ្តុំភស្តុតាងផ្សេងៗ

-ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការតាមដីកាតុលាការ

-ទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អង្គការ អយ្យការ និង អាជ្ញាធរតុលាការមានសមត្ថកិច្ច ។

### គ.បំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងយោធា :

-ទទួលបន្ទុករក្សាសុវត្ថិភាព និង បំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និង អាជ្ញាធរជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ។

-ការពារទីតាំងយោធា

-កិច្ចការប៉ូលីសយោធានៅក្នុង និង ក្រៅទីតាំងកងទ័ព

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង អាជ្ញាធរយោធា មានសមត្ថកិច្ច ។

ឃ-ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់ ។

**មាត្រា ៥ :** កងរាជអាវុធហត្ថអាចនឹងទទួលបេសកកម្មផ្នែកប៉ូលីស ពិសេសបន្ថែមដោយអនុលោម តាមអនុក្រឹត្យក្នុងបច្ចុកាល ។

**មាត្រា ៦ :** រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថមាន ÷

-អធិការដ្ឋានកងរាជអាវុធហត្ថទទួលខុសត្រូវដោយអធិការមួយរូប និង អធិការរងមួយរូប ។

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថទទួលខុសត្រូវដោយមេបញ្ជាការមួយរូប និងមេបញ្ជាការរងមួយរូប

**មាត្រា ៧ :** អធិការដ្ឋានកងរាជអាវុធហត្ថ

អធិការ និង អធិការរងកងរាជអាវុធហត្ថមានភារកិច្ចបំពេញ បេសកកម្មត្រួតពិនិត្យសិក្សា និង ផ្តល់ពត៌មាន ។

អធិការ និង អធិការរងកងរាជអាវុធហត្ថត្រូវស្ថិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ដែលជាអ្នកកំណត់បេសក កម្ម ។

អធិការ និង អធិការរងកងរាជអាវុធហត្ថជាទីប្រឹក្សាអចិន្ត្រៃយ៍របស់នាយករដ្ឋមន្ត្រី ។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ ត្រូវផ្តល់យោបល់ដល់នាយក រដ្ឋមន្ត្រី នូវគំរោងស្តីពីអនាគតផ្នែករចនាសម្ព័ន្ធ និង មុខងាររបស់កងរាជអាវុធហត្ថ ។ អធិការកងរាជអាវុធហត្ថតែងតែតាមពិនិត្យមើល ដោយផ្ទាល់នូវកិច្ចប្រតិបត្តិការងារ និង ការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថអោយសមស្របតាមក្បួនច្បាប់ ។

**មាត្រា ៨ :** បញ្ជាការដ្ឋានកងរាជអាវុធហត្ថ

បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយបញ្ជាការថ្នាក់ឧត្តម សេនីយនិងមេបញ្ជាការរងមួយរូបមានភារកិច្ច ÷

-ចងក្រងបទបញ្ញត្តិការងារទូទៅ និងតាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធដូចជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ជាដើម ។

ផ្ដល់ព័ត៌មានដល់នាយករដ្ឋមន្ត្រី អំពីមធ្យោបាយគ្រប់បែបយ៉ាងដែលមានភាពបំពេញការងារបាន ។

-ដោះស្រាយកែសម្រួលចំពោះបញ្ហាទាក់ទងក្នុងការរៀបចំផ្នែករដ្ឋបាល និង ដំណើរការប្រព្រឹត្តិទៅរបស់កងរាជអាវុធហត្ថ ។

ឋិតនៅក្រោមបញ្ជារបស់មេបញ្ជាការ និង មេបញ្ជាការរងកងរាជអាវុធហត្ថមាន ÷

-សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ

-កងរាជអាវុធហត្ថផ្ទៃប្រទេស

-កងរាជអាវុធហត្ថចល័ត

-តម្រួតយោធា

**មាត្រា ៩ :** សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ :

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថត្រូវទទួលបន្ទុក ÷

-រៀបចំកម្មវិធីបង្រៀន

-ហ្វឹកហ្វឺនបុគ្គលិក

-ត្រួតពិនិត្យការហ្វឹកហ្វឺន

-រៀបរៀង និង ចងក្រងឯកសារសំរាប់បង្រៀន

-ធ្វើសំណើទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថ នូវ សំភារៈជាចាំបាច់សំរាប់ ដំណើរការសិក្សាអោយមានប្រសិទ្ធភាព

**មាត្រា ១០:** កងរាជអាវុធហត្ថផ្ទៃប្រទេស :

កងរាជអាវុធហត្ថផ្ទៃប្រទេស ដែលដាក់អោយអនុវត្តការងារនៅពេញផ្ទៃ ព្រះរាជាណាចក្រកម្ពុជារហូតទៅដល់ថ្នាក់ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកកម្មរបស់ កងរាជអាវុធហត្ថដែលមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ។

សមត្ថកិច្ចនៃកងរាជអាវុធហត្ថផ្ទៃប្រទេសអនុវត្តទៅលើពលរដ្ឋស៊ីវិល និង យោធា។

**មាត្រា ១១:** កងរាជអាវុធហត្ថចល័ត

ជាកងកំលាំងសំរាប់រ៉ាប់រងអោយមានសណ្ដាប់ធ្នាប់ និងប្រយុទ្ធប្រឆាំង នឹងក្រុមប្រដាប់អាវុធខុសច្បាប់ ។ កងរាជអាវុធហត្ថចល័តអនុវត្តការងារពេញផ្ទៃប្រទេសតាមការស្នើ

សុំពីកងរាជអាវុធ ហត្ថផ្ទៃប្រទេស ឬ តាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ច ផ្នែករដ្ឋបាល ឬ តុលាការ ។ កងរាជអាវុធហត្ថចល័តត្រូវត្រៀមខ្លួនជានិច្ចសំរាប់បន្ថែមកំលាំង ក្នុងពេលខ្លីបំផុត ទៅជួយកងឯកភាពនៃកងរាជអាវុធហត្ថផ្ទៃប្រទេស ។

**មាត្រា ១២ :** តម្រួតយោធា :

តម្រួតយោធា គឺជាកងកំលាំងមួយនៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះទៅធ្វើការ ផ្ទាល់ជាមួយនឹងកងទ័ពទាំងបីប្រភេទ នៃ កងយោធពលខេមរភូមិន្ទ ។ តម្រួតយោធាបំពេញ បេសកកម្មនេះក្រោមបញ្ជាអាជ្ញាធរដូចមានចែងក្នុងវគ្គ "គ" នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៣ :** អធិការ ឬមេបញ្ជាការរងកងរាជអាវុធហត្ថអាចស្នើបង្កើននូវ អង្គភាពឯកទេសផ្សេងៗ ទៀត ដើម្បីប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

**មាត្រា ១៤ :** នាយករដ្ឋមន្ត្រីសំរេចកំណត់ភារកិច្ចចំនួនជាក់ស្តែង និង ការតែងតាំងក្នុងការរៀបចំស្ថាប័នលើ សំណើពីមេបញ្ជាការ និង អធិការកងរាជអាវុធហត្ថដែលបានពិភាក្សាឯកភាពរួចជាមួយ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អគ្គសេនាធិការកង យោធពលខេមរភូមិន្ទ ។

**មាត្រា ១៥ :** អនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩៤ ព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ អំពីអនុក្រឹត្យ នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយកអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង គ្រប់ក្រសួង ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***